# កិច្ចពិភាក្សាប្រចាំឆ្នាំ
# ស្តីពី
# ជំនាញមជ្ឈត្តការពាណិជ្ជកម្ម និងតុលាការកម្ពុជា

មជ្ឈត្តការពាណិជ្ជកម្ម (ការដោះស្រាយវិវាទដោយផ្អែកលើការសម្រេចរបស់អាជ្ញាកណ្តាលពាណិជ្ជកម្ម) ជាជំនាញថ្មីដែលមាននៅក្នុងប្រទេសកម្ពុជា ។ ប៉ុន្តែវាជាជំនាញដែលទំនើប និងពេញនិយមនៅលើសកលលោក ។ វិវាទពាណិជ្ជកម្មជាច្រើនត្រូវបានដោះស្រាយតាមរយៈជំនាញនេះនៅក្រៅតុលាការ និងគាំទ្រសហប្រតិបត្តិការពីតុលាការ ក្នុងការអនុវត្តនីតិវិធីផ្សេងៗដែលមានការពាក់ព័ន្ធ ក្នុងគោលបំណងធ្វើឲ្យយន្តការនេះមានប្រសិទ្ធិភាព អនុវត្តដោយបង្ខំដូចតុលាការដែរ ហើយជាហេតុធ្វើឲ្យវាទទួលបានឋានៈជាតុលាការឯកជនដែលមានយុត្តិធម៌ អព្យាក្រឹត្យ និងឯករាជ្យ ។ ដោយមើលឃើញពីសារៈប្រយោជន៍យ៉ាងនេះ ទើបនៅថ្ងៃទី១៤-វិច្ឆិកា-២០១៤ មានការណាត់ជួបពិភាក្សាគ្នារវាងស្ថាប័នដែលគ្រប់គ្រងមជ្ឈត្តករ (ម.ជ.ម.) និងតុលាការកម្ពុជា ព្រមទាំងស្ថាប័នច្បាប់ដ៏ទៃទៀត ដូចជាក្រសួងយុត្តិធម៌ គណៈមេធាវី ជាដើម ។ល។ ដើម្បីពិនិត្យមើលពីខ្លឹមសារច្បាប់មជ្ឈត្តការពាណិជ្ជកម្មកម្ពុជា និងទំនាក់ទំនងរវាងជំនាញនេះជាមួយតុលាការ និងបណ្តាអង្គភាពដែលពាក់ព័ន្ធផ្សេងៗទៀតយ៉ាងណាខ្លះ? តើលទ្ធផលនៃកិច្ចពិភាក្សាសម្រេចបានអ្វីខ្លះ?

ការពិភាក្សារយៈពេល ១ថ្ងៃ ប្រព្រឹត្តទៅរវាងមជ្ឈត្តករ (អាជ្ញាកណ្តាល) ចៅក្រម ព្រះរាជអាជ្ញា មេធាវី អ្នកច្បាប់នៃស្ថាប័នផ្សេងៗ ជំនាញការអន្តរជាតិ...។ល។ ធ្វើឲ្យរកឃើញនូវចំនុចមួយចំនួចរួមមានៈ ការបានអនុវត្តតាមច្បាប់មជ្ឈត្តការពាណិជ្ជកម្មកម្ពុជា អនុវត្តបង្កើតស្ថាប័នម.ជ.ម.ស្របតាមអនុក្រឹត្យរបស់រាជរដ្ឋាភិបាល និង ប្រទេសកម្ពុជាមានមជ្ឈត្តកររបស់ខ្លួនដែលមានស្តង់ដារដូចប្រទេសជឿនលឿនដែរ ។ ការអនុវត្តសេចក្តីសម្រេចរបស់មជ្ឈត្តករ (មជ្ឈត្តវិនិច្ឆ័យ) មានការទទួលស្គាល់ពីតុលាការជាន់ខ្ពស់ក្នុងការអនុវត្តដោយបង្ខំ និងដីកាផ្សេងៗទៀតត្រឹមសាលាដំបូងខេត្ត-ក្រុងដែលទាំងនេះគួរមានជា"បែបគំរូ" ដើម្បីងាយស្រួលក្នុងការអនុវត្ត ។

សរុបសេចក្តីមក កិច្ចពិភាក្សាក្នុងថ្ងៃនេះ ពិតមែនតែជាលើកដំបូង ក៏ប៉ុន្តែវាជាប្រវត្តិសាស្រ្តរបស់ប្រទេសកម្ពុជា ដែលមានវត្តមានយន្តការដោះស្រាយវិវាទពាណិជ្ជកម្មក្រៅតុលាការ-តុលាការ និងអ្នកច្បាប់នៃប្រទេសនេះ មូលមតិគ្នាដើម្បីធ្វើឲ្យសំរេចគោលបំណងរបស់ជាតិខ្លួន ។ លើសពីនេះវាក៏បានត្រួសត្រាយផ្លូវក្នុងកិច្ចសហប្រតិបត្តិការអនុវត្តមជ្ឈត្តវិនិច្ឆ័យ និង ខ្លឹមសារច្បាប់មជ្ឈត្តការពាណិជ្ជកម្ម ឲ្យមានលក្ខណៈរលូន ល្អប្រសើរនាពេលអនាគត ។ ដើម្បីសំរេចគោលបំណងទាំងនេះ អង្គសិក្ខាសាលាបានឯកភាពឲ្យមានការជួបពិភាក្សាគ្នាបែបនេះជារៀងរាល់ឆ្នាំ ៕


Annual National Conference
On
Interaction Between
National Courts And Commercial Arbitration
Presided over by
H.E. Ang Vong Vattana
Minister of justice
Raffles Hotel Le Royal, November 14, 2014
IFC


MoJ
MoJ






ដោយ៖ **អូវីធី ដោះស្រាយវិវាទ**

www.ouchvutthy.wordpress.com